1. In the event of serious balance of payments and external financial difficulties or threat thereof, a Member State may adopt or maintain restrictions on investments on which it has undertaken specific commitments, including on payments or transfers for transactions related to such commitments. It is recognised that particular pressures on the balance of payments of a Member State in the process of economic development or economic transition may necessitate the use of restrictions to ensure, inter alia, the maintenance of a level of financial reserves adequate for the implementation of its programme of economic development or economic transition.
2. Where measures to safeguard balance of payments are taken pursuant to this Article notice of such measures shall be given to the AIA Council within 14 days from the date such measures are taken.
3. The measures referred to in paragraph (1):

   (a) shall not discriminate among Member States;

   (b) shall be consistent with the Articles of Agreement of the International Monetary Fund;

   (c) shall avoid unnecessary damage to the commercial, economic and financial interests of any other Member State;

   (d) shall not exceed those necessary to deal with the circumstances described in paragraph I; and

   (e) shall be temporary and be phased out progressively as the situation specified in paragraph 1 improves.

4. The Member States adopting the balance of payments measures shall commence consultations with the AIA Council and other Member States within 90 days from the date of notification in order to review the balance of payment measures adopted by it.
5. The **AIA** Council shall determine the rules applicable to the procedures under this Article.

## ARTICLE 16
## Institutional Arrangements

1. The ASEAN Economic Ministers (AEM) shall establish an ASEAN Investment Area Council (in this Agreement referred to as "the AIA Council") comprising the Ministers responsible for investment and the Secretary General of ASEAN. The ASEAN Heads of Investment Agencies shall participate in the AIA Council meetings.
2. Notwithstanding Article 21 of this Agreement, the AIA Council shall be established upon the signing of this Agreement.

3. The AIA Council shall supervise, co-ordinate and review the implementation of this Agreement and assist the AEM in all matters relating thereto.
4. In the performance of its functions, the AIA Council shall establish a Coordinating Committee on Investment (CCI) comprising senior officials responsible for investment and other senior officials from relevant government agencies.
5. The Co-ordinating Committee on Investment shall report to the AIA Council through the Senior Economic Officials Meeting (SEOM).
6. The ASEAN Secretariat shall be the secretariat to the AIA Council and the Co-ordinating Committee on Investment (CCI).

**ARTICLE 17**
**Settlement of Disputes**

1. The Protocol on Dispute Settlement Mechanism for ASEAN shall apply in relation to any dispute arising from, or any differences between Member States concerning the interpretation or application of this Agreement or any arrangement arising therefrom.
2. If necessary, a specific dispute settlement mechanism may be established for the purpose of this Agreement which shall form an integral part of this Agreement.

**ARTICLE 18**
**Amendments**

Any amendments to this Agreement shall be made by consensus and shall become effective upon the deposit of instruments of ratification or acceptance by all signatory governments with the Secretary-General of ASEAN.

**ARTICLE 19**
**Supplementary Agreements or Arrangements**

The Schedules, Action Plans, Annexes, and any other arrangements agreements arising under this Agreement shall form an integral part of this Agreement.

**ARTICLE 20**
**Accession of New Members**

New members of ASEAN shall accede to this Agreement on terms and conditions agreed between them and signatories to this Agreement and by depositing the instrument of accession with the Secretary-General of ASEAN.

**ARTICLE 21**
**Final Provisions**

1. This Agreement shall enter into force upon the deposit of instruments of ratification or acceptance by all signatory governments with the Secretary General of ASEAN. The signatory governments

undertake to deposit their instruments of ratification or acceptance within 6 months after the date of signing of this Agreement.

2. This Agreement shall be deposited with the Secretary-General of ASEAN, who shall promptly furnish a certified copy thereof to each Member State.

**IN WITNESS WHEREOF**, the undersigned being duly authorized by their respective Governments, have signed this Framework Agreement on the ASEAN Investment Area.

DONE **at Makati, Philippines this 7th day of October 1998**, in a single copy in the English language.

For the Government of Brunei Darussalam
**(Sgd.)ABDUL RAHMAN TAIB**
Minister of Industry and Primary Resources

For the Government of the Republic of Indonesia
**(Sgd.) HAMZAH HAZ**
Minister of Investment/chairman of Investment Coordinating Board

For the Government of the Lao People's Democratic Republic

**(Sgd.) SOULIVONG DARAVONG**
Minister of Industry and Handicrafts

For the Government of Malaysia
**(Sgd.) RAFIDAH AZIZ**
Minister of International Trade and Industry

For the Government of the Union of Myanmar
**(Sgd.) BRIGADIER GENERAL DAVID O. ABEL**
Minister at the Office of the Chairman of the State Peace and Development Council

For the Government of the Republic of the Philippines
**(Sgd.) JOSE TRINIDAD PARDO**
Secretary of Trade and Industry

For the Government of the Republic of Singapore
**(Sgd.) LEE YOCK SUAN**
Minister for Trade and Industry

For the Government of the Kingdom of Thailand
**(Sgd.) SUPACHAI PANITCHPAKDI**
Deputy Prime Minister and Minister of Commerce

For the Government of the Socialist Republic of Vietnam
**(Sgd.) TRUONG DINH TUYEN**
Minister of Trade

# ព្រះរាជក្រឹត្យ

នស/រកត/១១០៥/៤៥៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានរដ្ឋសភាស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង :

- ឯកឧត្តម ម៉ត់ ពេជ្ជវិទ្ធ ជាទីប្រឹក្សាផ្ទាល់សម្តេច **ហេង សំរិន** អនុប្រធានទី១ នៃរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។
- ឯកឧត្តម តាន់ យឹមនាយ ជាទីប្រឹក្សាផ្ទាល់សម្តេច **ហេង សំរិន** អនុប្រធានទី១ នៃរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។
- ឯកឧត្តម គ្រួស សារ៉ុម ជាទីប្រឹក្សាផ្ទាល់សម្តេច **ហេង សំរិន** អនុប្រធានទី១ នៃរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។
- លោកជំទាវ ចម និម្មល ជាទីប្រឹក្សាផ្ទាល់សម្តេច **ហេង សំរិន** អនុប្រធានទី១ នៃរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ :** ប្រធានរដ្ឋសភា និង នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*ថ្ងៃនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥*

*៣រល.០៥១១.៤៩០*

លេខ ៤៣០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ១១ ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ាវ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០៥/៤៥៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានបញ្ឈប់តំណែងឯកឧត្តម ហែម កេតសន្ធា ពីទីប្រឹក្សាផ្ទាល់សម្តេច នរោត្តម សិរីវុឌ្ឍ ឧបនាយករដ្ឋមន្ត្រី ។

**មាត្រា ២ :** ត្រូវបានតែងតាំងឯកឧត្តម ផាត់ ព្រីឌី ជាទីប្រឹក្សាផ្ទាល់សម្តេច នរោត្តម សិរីវុឌ្ឍ ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ អនុរដ្ឋលេខាធិការ ជំនួសឯកឧត្តម ហែម កេតសន្ធា ដែលត្រូវបានបញ្ឈប់ពីមុខតំណែង ។

**មាត្រា ៣ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១ល.០៩១១-៤៩១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ២០០៥

លេខ ៤៩៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០៥/៤៦៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០០៤/០០៤ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០០៤/០០៦ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់វិសោធនកម្មច្បាប់ ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំងថ្នាក់ដឹកនាំនៃការិយាល័យរដ្ឋបាល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាល នៃកម្ពុជាប្រជាធិបតេយ្យ :

១-ឯកឧត្តម **ស៊ាន វិសុទ្ធ** ជាប្រធានការិយាល័យរដ្ឋបាល

២-ឯកឧត្តម **ហែម ក្រាញ់ តូនី** ជាប្រធានការិយាល័យរដ្ឋបាលបំរុង

**មាត្រា២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៥១១.៤៩៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥

លេខ : ៤៣៥ . ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១១០៥/៤៦៣

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្ម ដល់លោក ស៊ុ អាយមីន (XU AIMIN) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៦២ នៅក្រុងគ័នចូវ សាធារណរដ្ឋប្រជាមានិតចិន ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៤៣៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាឌី តាន់

៣៖ល.០៥១១.៤៩៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៥

នស/រកត/១១០៥/៤៦៤

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក លី ឆីខឿង (LEE CHI KEUNG) សញ្ជាតិចិន ជនជាតិចិន កើតថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៦៦ នៅក្រុងហុងកុង ប្រទេសចិន ដោយប្តូរឈ្មោះ ជា លី ឆីខេង (LEE CHI KHENG) ។

**មាត្រា ២:** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១ស-០៥១១-៤៩៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៥

លេខៈ ៤០៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០០
អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ អាន

នស/រកត/១១០៥/៥០៥

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម **ស៊ុយ សែម**

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤.០៥១១.៥០០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ.ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥

លេខ ៨៤០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ.ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស្វាយ តាន់**

ព្រះរាជក្រឹត្យ

នស/រកត/១១០៥/៤៦៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០០៤/០០៤ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០០៤/០០៦ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់វិសោធនកម្មច្បាប់ ស្តីពីការបង្កើតឱ្យមានសាលាក្តីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំងលោកស្រី មីសែល លី (Michelle Lee) ជាអនុប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។

**មាត្រា២:** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ព.ស.០៥១១.៥០១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០០៥

លេខ ៤៣៧ ច.ល
ដើម្បីចម្លងចែកចាយ
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សូ៊ី ភាន

នស/រកត/១១០៥/៤៦៧

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគូបិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :
-ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

១-ឯកឧត្តម ព្រាប ស៊ិន
២-ឯកឧត្តម តាន់ ទុដ្ឋា
៣-ឯកឧត្តម ខៀវ មុត
៤-ឯកឧត្តម ខុង សំនួន
៥-ឯកឧត្តម យិន គីមសាន

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :

១-ឯកឧត្តម ចឹក គ្រឿនវុត្ថា
២-ឯកឧត្តម ស៊ិន ខាន់ឌី
៣-ឯកឧត្តម អៀម រ៉ា
៤-លោកជំទាវ មាស ម៉ារិន
៥-ឯកឧត្តម ឆា ឌុម

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល-០៥១១.៥០៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០០៥

លេខ : ៤៦៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សូ ស៊ី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០៥/៤៦៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់ឱ្យប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងលោកជំទាវ ជា សំអេង ជាទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** តម្លើងឋានៈឯកឧត្តម ជា សុធន នាយករងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា ៣ :** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេច ព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៥១១-៥០៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥*

លេខ ៤៤១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ំ អ៊ី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១១០៥/៤៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់នាយឧត្តមសេនីយ៍ផ្កាយមាស ៤ ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម :

១-ឧត្តមសេនីយ៍ឯក ម៉ុ ឆន អត្តលេខ ០០០០២២

២-ឧត្តមសេនីយ៍ឯក ស៊ើយ កែវ អត្តលេខ ០០០០៣៧

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧ល.០៥១១.៥០៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០០៥

លេខ ១៣៧៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ១១ ឆ្នាំ២០០៥
អគ្គលេខាធិការរងនៃរដ្ឋាភិបាល
[illegible]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១៣២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្តល់ឥណទានថវិកាបន្ថែមលើឥណទានថវិកា របស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧, ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤, ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១២០៤/ ០០២ .ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ដោយអនុលោមទៅតាមមាត្រា ៤៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១/ នស/៩៣.ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានអនុញ្ញាតផ្តល់បន្ថែមឥណទានថវិកា ចំនួន ៦.៤០០ លានរៀល ( ប្រាំមួយពាន់បួនរយលានរៀលគត់ ) ទៅលើសៀវភៅថវិការបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។

**មាត្រា២:** ឥណទានថវិកាបន្ថែមដូចបានកំណត់ក្នុងប្រការ ១ ខាងលើត្រូវបានបន្ថែមនូវជំពូក ១១ " ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច " ចំនួន ៦.១១៦ លានរៀល ( ប្រាំមួយពាន់មួយរយដប់ប្រាំមួយលានរៀលគត់) និងជំពូក ៣២ ( អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ ) ចំនួន ២៨៤ លានរៀល ( ពីររយប៉ែតសិបបួនលានរៀលគត់ ) ជូនក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ សំរាប់ដំណើរការចំណាយដល់ស្ថានទូតថ្មីដែលបានបើកហើយនៅ ក្រុងឡុងដ៍ ប្រ៊ុចសែល និងប៉ូឡូញ និងស្ថានអគ្គកុងស៊ុលថ្មីនៅគុនមីញ និង ឆុងឈីង និងបង់វិភាគទានជូនអង្គការអន្តរជាតិផ្សេងៗ ។

**មាត្រា៣:** ការបែងចែកឥណទានថវិកាបន្ថែមផ្ទៃក្នុងជំពូក តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា៤:** ឥណទានថវិកាបន្ថែមនេះ ត្រូវបានរដ្ឋសភាពិនិត្យអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុ នាពេលខាងមុខកាលបើចំណាយពិសេសនេះត្រូវបានចប់សព្វគ្រប់ ។

**មាត្រា៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ..១៣៣...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៧ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីរបបសារព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៥ ។

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងរួមចំណែកក្នុងការផ្តល់នូវអាហារូបត្ថម្ភឱ្យបានសព្វគ្រប់ និងមានសុវត្ថិភាពដល់ ទារក និងកុមារតូចៗ តាមរយៈ ការគាំពារ និងការលើកកម្ពស់ការបំបៅកូនដោយទឹកដោះម្តាយ និងការជំរុញលើកទឹកចិត្តឱ្យមានការផ្តល់អាហារបន្ថែមឱ្យបានត្រឹមត្រូវ និងស្របតាមអាយុកំណត់របស់ទារក និងកុមារ ដើម្បីធានាឱ្យមានការប្រើប្រាស់សមស្របនូវផលិតផលជំនួសទឹកដោះម្តាយតែនៅពេលណាដែលចាំបាច់ និងដោយមានមូលដ្ឋានព័ត៌មានគ្រប់គ្រាន់ ។

**មាត្រា ២.-**

អនុក្រឹត្យនេះ កំណត់អំពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ក្នុងនោះមានផលិតផល ដែលផលិតក្នុងប្រទេស និងផលិតផលនាំចូលពីបរទេស សម្រាប់បម្រើតម្រូវការប្រើប្រាស់ក្នុងការចិញ្ចឹមទារក រហូតដល់អាយុគ្រប់ ១២ ខែ និងកុមារតូចៗរហូតដល់អាយុ ២៤ ខែ ។

អនុក្រឹត្យនេះ មានអានុភាព និងត្រូវអនុវត្តចំពោះ គុណភាព និងវត្តមាន នៃព័ត៌មានទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ផលិតផលដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ។

**មាត្រា ៣.-**

ប្រភេទផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ រួមមាន ៖

ក- ទឹកដោះគោម្សៅផ្សំតាមរូបមន្ត រួមបញ្ចូលទាំង ទឹកដោះគោម្សៅផ្សំតាមរូបមន្តពិសេស ។

ខ- រាល់ផលិតផលទាំងអស់ដែលត្រូវបានផ្សព្វផ្សាយលក់ ឬបញ្ជាក់បង្ហាញថា សមស្របសម្រាប់ចិញ្ចឹមទារក និងកុមារតូចៗ ។

គ- ដបបំបៅ ក្បាលដោះដៃ និងគ្រឿងសម្រាប់ទារកជញ្ជក់លេង ។

ឃ- ទឹកដោះគោផ្សំតាមរូបមន្ត សម្រាប់កុមារចាប់ពីអាយុ ៦ ខែ ។

ង- ផលិតផលផ្សេងទៀតដែលត្រូវបានកំណត់ដោយប្រកាសរួមរវាងក្រសួងសុខាភិបាល និងក្រសួងពាក់ព័ន្ធ។

# ជំពូកទី ២

# និយមន័យ

**មាត្រា ៤.-**

បច្ចេកស័ព្ទខាងក្រោម សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តអនុក្រឹត្យនេះ ÷

១- **ការឃោសនាពាណិជ្ជកម្ម** សំដៅដល់ គ្រប់ទង្វើទាំងអស់របស់ផលិតករ អ្នកនាំចូល ឬអ្នកចែកចាយ ទោះជាតាមមធ្យោបាយណាក៏ដោយដែលមាន គោលបំណងផ្សព្វផ្សាយលក់ ចែកចាយ ប្រើប្រាស់ ឬដាក់តាំងលក់ផលិតផលដែលមានចែងនៅក្នុងអនុក្រឹត្យនេះ ។ ខាងក្រោមនេះ គឺជាផ្នែកមួយនៃការឃោសនា ពាណិជ្ជកម្ម ÷

ក- ការបោះពុម្ពផ្សាយ ការផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ ភាពយន្ត ប្រព័ន្ធអេឡិចត្រូនិច កាសែតវីដេអូ ឬ តាមទូរស័ព្ទ ។

ខ- ការដាក់តាំងបង្ហាញផ្លាកសញ្ញាពាណិជ្ជកម្ម ផ្ទាំងព័ត៌មាន ផ្ទាំងរូបភាព ឬការបិទផ្សាយនានា ។

គ- ការដាក់តាំងពិពណ៌រូបភាព ឬគំរូផលិតផលផ្សេងៗ ។

២- **សម្ភារៈផ្គត់ផ្គង់** សំដៅដល់ ផលិតផលក្នុងបរិមាណមួយ ដែលត្រូវផ្ដល់អោយសម្រាប់ប្រើប្រាស់ ក្នុងរយៈពេលមួយកំណត់ ដោយឥតគិតថ្លៃ ឬក្នុងតម្លៃទាប (ទាបជាងតម្លៃលក់រាយចំនួន ៨០ ភាគរយ) សម្រាប់គោលដៅសង្គមកិច្ច ដោយរាប់បញ្ចូលទាំង សម្ភារៈដែលត្រូវផ្ដល់អោយក្រុមគ្រួសារដែលជួបប្រទះការខ្វះខាត ។

៣- **ការផ្សព្វផ្សាយលើកកម្ពស់ការប្រើប្រាស់** សំដៅដល់ គ្រប់វិធីសាស្ត្រទាំងអស់ ដែលត្រូវប្រើប្រាស់ ទោះផ្ទាល់ក្ដី ប្រយោលក្ដី ដើម្បីជំរុញលើកទឹកចិត្តអោយបុគ្គលប្រើប្រាស់ផលិតផល ដែលមានចែងនៅក្នុងអនុក្រឹត្យនេះ ។

៤- **ការផ្សព្វផ្សាយលក់** សំដៅដល់ ការផ្សព្វផ្សាយលក់ផលិតផល ការចែកចាយ ការឃោសនាពាណិជ្ជកម្ម ទំនាក់ទំនងសាធារណៈអំពីផលិតផល និងសេវាផ្សព្វផ្សាយព័ត៌មាន ។

៥- **កុមារតូចៗ** សំដៅដល់ កុមារចាប់ពីអាយុពី១២ ខែ រហូតដល់ ២៤ ខែ ។

៦- **គំរូសាក** សំដៅដល់ ផលិតផលក្នុងបរិមាណមួយតិចតួច ដែលត្រូវបានផ្ដល់អោយដោយឥតគិតថ្លៃ ។

៧- **គ្រឿងសម្រាប់ទារកជញ្ជក់លេង** សំដៅដល់ ក្បាលដោះសិប្បនិម្មិត សម្រាប់ទារកជញ្ជក់ ដែលអាចហៅថា ក្បាលដោះជ័រផងដែរ ។

៨- **បុគ្គលិកសុខាភិបាល** សំដៅដល់ បុគ្គលដែលផ្ដល់សេវាថែទាំសុខភាព ឬ បុគ្គលកំពុងទទួលការបណ្ដុះបណ្ដាលអំពីផ្នែកថែទាំសុខភាព នៅក្នុងប្រព័ន្ធថែទាំសុខភាព ទោះបីជាមានមុខវិជ្ជាជីវៈ ឬមិនមានមុខវិជ្ជាជីវៈ ក៏ដោយ រាប់បញ្ចូលទាំង ឆ្មបបុរាណ បុគ្គលិកស្ម័គ្រចិត្ត និងបុគ្គលិកមិនមានប្រាក់បៀវត្សរ៍ ។

៩- **បុគ្គលិកផ្នែកផ្សព្វផ្សាយលក់** សំដៅដល់ បុគ្គលដែលមានមុខងារពាក់ព័ន្ធនឹងការផ្សព្វផ្សាយលក់ផលិតផល ដែលមាននៅក្នុងវិសាលភាពនៃអនុក្រឹត្យនេះ ។

១០- **ប្រព័ន្ធថែទាំសុខភាព** សំដៅដល់ ស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ឬស្ថាប័នឯកជន

ដែលចូលរួមដោយផ្ទាល់ ឬដោយប្រយោល ក្នុងការថែទាំសុខភាព ឬការអប់រំសុខភាព ដល់ស្ត្រីជាមាតាទារក និងស្ត្រីមានផ្ទៃពោះ ដោយរាប់បញ្ចូលទាំងទារកដ្ឋាន និងមជ្ឈមណ្ឌលថែទាំទារក និងកុមារ ។ បុគ្គលិកថែទាំសុខភាព នៅក្នុងវិស័យឯកជន ក៏ស្ថិតនៅក្នុងប្រព័ន្ធនេះដែរ ។

១១- **ស្លាកសញ្ញា** សំដៅដល់ រាល់ផ្លាកសញ្ញាពាណិជ្ជកម្ម ម៉ាក រូបភាព ឬសេចក្ដីពិពណ៌នាផ្សេងៗ ដែលសរសេរជា លាយលក្ខណ៍អក្សរ បោះពុម្ព ផ្តិតស្តង់ស៊ីល គូស រំលេចជាក្បាច់ ឬស្លាម ឬបិទភ្ជាប់ទៅនឹង សម្បកផលិតផលទាំងអស់ ដែលមាននៅក្នុងខ្លឹមសារ និងវិសាលភាពនៃអនុក្រឹត្យនេះ ។

១២- **ការធ្វើស្លាក** សំដៅដល់ ការគិតបញ្ចូលនូវទាំងអ្វីៗដែលបានសរសេរ បោះពុម្ព ឬជាក្រាហ្វិកដែលបាន បង្ហាញនៅលើស្លាកផលិតផលទៅតាមចារិកពិតរបស់ចំណីអាហារ ឬបានដាក់បង្ហាញនៅជិតចំណីអាហារគិតទាំងអ្វី ដែលសម្រាប់បម្រើការផ្សព្វផ្សាយលក់ផងដែរ ។

១៣- **ផលិតផលជំនួសទឹកដោះម្ដាយ** សំដៅដល់ រាល់អាហារទាំងឡាយណាដែលត្រូវបានផ្សព្វផ្សាយលក់ ឬ ធ្វើការបង្ហាញ ដែលអាចជំនួសទឹកដោះម្ដាយមួយផ្នែកឬទាំងស្រុង ទោះសមស្រប ឬមិនសមស្របតាមគោលបំណងនេះ ក៏ដោយ ។

១៤- **ផលិតករ** សំដៅដល់ សាជីវកម្ម ឬអង្គភាពដទៃទៀតនៅក្នុងវិស័យសាធារណៈ ឬឯកជន ដែលមាន ការងារ ឬមុខងារធ្វើផលិតផលដែលស្ថិតនៅក្នុងវិសាលភាពនៃអនុក្រឹត្យនេះ ទោះជាដោយផ្ទាល់ក្ដី ឬតាមរយៈ ភ្នាក់ងារណាមួយក្ដី ឬតាមរយៈអង្គភាពក្រោមឱវាទក្ដី ឬជាប់កិច្ចសន្យាជាមួយនឹងខ្លួនក្ដី ។

១៥- **ទារក** សំដៅដល់ កុមារចាប់តាំងពីកើតរហូតដល់អាយុ ១២ ខែ ។

១៦- **ទឹកដោះគោម្សៅផ្សំតាមរូបមន្ត** សំដៅដល់ ផលិតផលជំនួសទឹកដោះម្ដាយ ដែលផលិតដោយរោងចក្រ តាមស្តង់ដារចំណីអាហារ (Codex Alimentarius) ដើម្បីបំពេញសេចក្ដីត្រូវការធម្មតារបស់ទារកចាប់ពីពេលកើត រហូតដល់អាយុ ៦ខែ ហើយ សមស្របទៅតាមលក្ខណៈសរីរៈសាស្ត្ររបស់កុមារ ។

១៧- **ទឹកដោះគោម្សៅផ្សំតាមរូបមន្តសម្រាប់បំប៉ន** សំដៅដល់ ទឹកដោះគោ ឬផលិតផលទឹកដោះគោ ដែល មានប្រភពមកពីសត្វ ឬបន្លែ ឬគ្រាប់ធញ្ញជាតិដែលត្រូវបានផលិតនៅក្នុងរោងចក្រ តាមស្តង់ដារចំណីអាហារ (Codex Alimentarius) ជាទឹកដោះគោម្សៅបំប៉ន ហើយត្រូវបានផ្សព្វផ្សាយលក់ ឬបង្ហាញថាសមស្របសម្រាប់ចិញ្ចឹមទារក និងកុមារដែលមានអាយុលើសពី ៦ ខែ ។

១៨- **ទឹកដោះគោម្សៅផ្សំតាមរូបមន្តពិសេស** សំដៅដល់ ទឹកដោះគោម្សៅផ្សំតាមរូបមន្ត សម្រាប់ទារកកើត មិនគ្រប់ខែ ឬទារកកើតមិនគ្រប់គីឡូ ឬសម្រាប់ទារកដែលមានប្រតិកម្មជាមួយនឹងទឹកដោះគោផ្ទាល់ ឬកាបូអ៊ីដ្រាត ឬ មានប្រព័ន្ធរាងកាយមិនប្រក្រតី ។

១៩- **សម្បកផលិតផល ឬកំប៉ុង** សំដៅដល់ រាល់ទម្រង់វេចខ្ចប់ផលិតផលដែលមាននៅក្នុងវិសាលភាពនៃ អនុក្រឹត្យនេះ សម្រាប់លក់ដូរ ដូចជា លក់រាយធម្មតា ដោយរាប់បញ្ចូលទាំងសម្បកកេសខាងក្រៅផងដែរ ។

២០- **អាហារបន្ថែម** សំដៅដល់អាហារទាំងឡាយណា ទោះជាផលិតនៅក្នុងរោងចក្រ ឬធ្វើនៅតាមផ្ទះក្តី ដែលអាចបំពេញបន្ថែមទៅលើទឹកដោះម្តាយ នៅពេលដែលទឹកដោះម្តាយតែមួយមុខមិនគ្រប់គ្រាន់ សម្រាប់បំពេញសេចក្តីត្រូវការរបស់ទារក នៅពេលអាយុបាន ៦ ខែ ។

២១- **អ្នកចែកចាយ** សំដៅដល់បុគ្គល សាជីវកម្ម ឬអង្គភាពដទៃទៀត នៅក្នុងវិស័យសាធារណៈ ឬឯកជន ដែលមានមុខងារផ្សព្វផ្សាយលក់ដុំ ឬលក់រាយនូវផលិតផលដែលមាននៅក្នុងវិសាលភាពនៃអនុក្រឹត្យនេះ ទោះបីដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ។

២២- **អ្នកចែកចាយបឋម** សំដៅដល់ ភ្នាក់ងារលក់របស់អ្នកផលិត អ្នកតំណាង អ្នកចែកចាយក្នុងប្រទេស ឬអ្នកជើងសារ ។

២៣- **មន្ត្រីត្រួតពិនិត្យ** សំដៅដល់បុគ្គលដែលត្រូវបានតែងតាំង នៅក្រោមសមត្ថកិច្ចរបស់នាយកដ្ឋានឱសថ ចំណីអាហារ គ្រឿងសម្ភារៈ និងបរិក្ខារពេទ្យ ជាមន្ត្រីត្រួតពិនិត្យ ដែលរដ្ឋមន្ត្រីក្រសួងសុខាភិបាលបានផ្តល់សិទ្ធិអំណាចអោយ ដើម្បីអនុវត្តមុខងារនេះ តាមការចាំបាច់ ស្របតាមបញ្ញត្តិនៃអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

## ជំពូកទី ៣
## ការដាក់កម្រិតលើការផ្សព្វផ្សាយ
## ព័ត៌មាន និងការអប់រំ

**មាត្រា ៥.-**

ក្រសួងសុខាភិបាលមានភារកិច្ចដាក់ចេញនូវគោលនយោបាយ និងផ្តល់ជូននូវព័ត៌មានសមស្របស្តីពីការចិញ្ចឹមទារក និងកុមារតូចៗដល់ក្រុមគ្រួសារ និងមន្ត្រីទាំងឡាយដែលធ្វើការពាក់ព័ន្ធនឹងផ្នែកអាហារូបត្ថម្ភទារក និងកុមារតូចៗ ដើម្បីឱ្យមានការយល់ដឹងអំពីវិធីផ្តល់ចំណីអាហារដល់ទារក និងកុមារតូចៗតាមរយៈការផ្សព្វផ្សាយព័ត៌មាន និងការអប់រំ។ ក្នុងការអនុវត្តភារកិច្ចខាងលើនេះ ក្រសួងសុខាភិបាលត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធនានាដែលបម្រើវិស័យនេះ ក្នុងករណីចាំបាច់ ។

**មាត្រា ៦.-**

រាល់ព័ត៌មាន សម្ភារៈ ឬឯកសារអប់រំ ឬសម្ភារៈផ្សេងទៀត ទោះជាសរសេរជាលាយល័ក្ខណ៍អក្សរក្តី ថតជា សម្លេងក្តី ឬជារូបភាពក្តី ដែលទាក់ទងនឹងការចិញ្ចឹមទារក ដែលត្រូវបានផលិត និងរៀបចំឡើងដើម្បីប្រើនៅក្នុងប្រទេសដោយបុគ្គលណាក៏ដោយ ៖

១- ត្រូវពន្យល់ច្បាស់លាស់ពី ៖

ក- ផលប្រយោជន៍ និងឧត្តមភាពនៃការបំបៅកូនដោយទឹកដោះម្តាយ ។

ខ- របៀបផ្តួចផ្តើម និងបន្តការបំបៅកូនដោយទឹកដោះម្តាយ រួមបញ្ចូលទាំងអាហារូបត្ថម្ភសម្រាប់ម្តាយផង។

គ- អនុសាសន៍ឱ្យបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ រយៈពេល ៦ ខែ ចាប់ពីពេលកើត និងបន្តការបំបៅកូនដោយទឹកដោះម្តាយ ក្រោយរយៈពេល ៦ ខែ រហូតដល់កុមារមានអាយុបាន ២ ឆ្នាំ ឬលើស ។

ឃ- របៀបរបប និងមូលហេតុនៃការចាប់ផ្តើមបំបៅដោយដប ឬការឆាប់ចាប់ផ្តើមផ្តល់អាហារបន្ថែម។ ការបំបៅដោយដបឬការឆាប់ចាប់ផ្តើមផ្តល់អាហារបន្ថែមនេះ ពិតជាមានការរំខានដល់ការបំបៅកូនដោយទឹកដោះម្តាយ ទោះបីជាការបំបៅដោយដបនោះមានការកំណត់ត្រឹមតែ ២ ឬ ៣ ដង ក្នុងមួយថ្ងៃ ក៏ដោយ ។

២- ត្រូវមានព័ត៌មានត្រឹមត្រូវ និងថ្មីៗ និងមិនត្រូវប្រើរូបភាព ឬអត្ថបទណាមួយដែលជំរុញលើកទឹកចិត្តឱ្យមានការបំបៅដោយដប ឬរារាំងដល់ការបំបៅកូនដោយទឹកដោះម្តាយឡើយ ។

៣- ត្រូវសរសេរជាអក្សរខ្មែរ ។

៤- មិនត្រូវយោងទៅផលិតផលទាំងឡាយណាដែលមានចែងក្នុងអនុក្រឹត្យនិងបទប្បញ្ញត្តិជាធរមាន ឬមានប្រើឈ្មោះ និមិត្តសញ្ញា ផ្លាកសញ្ញាពាណិជ្ជកម្ម ឬសេចក្តីពិពណ៌នារបស់ផលិតករ ឬអ្នកចែកចាយផលិតផលជាដាច់ខាត លើកលែងតែការបង្ហាញតាមបែបការរក្សាសិទ្ធិប៉ុណ្ណោះ ។

**មាត្រា ៧.-**

ប្រសិនបើសម្ភារៈ ឬឯកសារ ឬព័ត៌មាន ដាក់បញ្ចូលប្រធានបទស្តីពីការចិញ្ចឹមទារកដោយផលិតផលជំនួសទឹកដោះម្តាយ តាមរយៈការបំបៅដោយដប សម្ភារៈឬឯកសារ ឬព័ត៌មាននោះ ត្រូវបញ្ជាក់អោយបានច្បាស់ជាអាទិ៍អំពី :

- ការរៀបចំ និងការប្រើប្រាស់ត្រឹមត្រូវនូវផលិតផលនោះ
- ការប៉ាន់ស្មានថវិកាចំណាយទៅលើផលិតផលសម្រាប់ចិញ្ចឹមទារករយៈពេល ៦ ខែ
- គ្រោះថ្នាក់ចំពោះសុខភាពដែលបណ្តាលមកពីការបំបៅដោយដប និងការរៀបចំពុំបានត្រឹមត្រូវនូវផលិតផល
- របៀបបញ្ចុកទារកដោយប្រើពែង

**មាត្រា ៨.-**

ប្រសិនបើសម្ភារៈ ឬឯកសារទាំងនោះ ដាក់បញ្ចូលប្រធានបទស្តីពីការចិញ្ចឹមទារក ដោយផ្តល់អាហារបន្ថែម សម្ភារៈ ឬឯកសារទាំងនោះ ត្រូវមានការពន្យល់ណែនាំអំពី ÷

- គ្រោះថ្នាក់ចំពោះសុខភាពដែលបណ្តាលមកពីការចាប់ផ្តើមឱ្យអាហារបន្ថែមមុនទារកអាយុបាន ៦ ខែ
- អាហារបន្ថែមទាំងនោះ អាចរៀបចំធ្វើបានដោយស្រួលនៅតាមផ្ទះ ដោយប្រើគ្រឿងផ្សំដែលមាននៅក្នុងមូលដ្ឋាន នៅតាមទីកន្លែងរស់នៅដែលងាយរកបាន
- ផលប្រយោជន៍ និងតម្លៃនៃការបន្តការបំបៅកូនដោយទឹកដោះម្តាយ ក្រោយពេលដែលកុមារអាយុបាន ៦ ខែ រហូតដល់កុមារមានអាយុ ២ ឆ្នាំ ឬលើស ។

## ជំពូកទី ៤

## ស្លាកសញ្ញា

**មាត្រា ៩.-**

ស្លាកសញ្ញានៃផលិតផលសម្រាប់ទារក និងកុមារ ក្រៅពីល័ក្ខខ័ណ្ឌតម្រូវដូចមានចែងក្នុងស្តង់ដារឧស្សាហកម្មកម្ពុជាត្រូវបង្ហាញបន្ថែមនូវខ្លឹមសារដូចខាងក្រោម ÷

ក- សម្បកផលិតផល ឬស្លាកដែលភ្ជាប់នោះមាន តួអក្សរដែលងាយស្រួលអានបាន ។

ខ- ពាក្យនិយាយថាគ្មានអ្វីប្រសើរជាងការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់រហូតបាន ៦ ខែ និងបន្តការបំបៅដោះម្តាយរហូតបានអាយុ ២ ឆ្នាំ ឬ លើសឡើយ ។

គ- ការណែនាំអំពីវិធីប្រើប្រាស់ និងការប្រើប្រាស់ និងការរៀបចំឱ្យបានត្រឹមត្រូវ ។

ឃ- បម្រាមដោយមានពាក្យកំណត់សម្គាល់អំពីគ្រោះថ្នាក់ដល់សុខភាព ដែលបណ្តាលមកពីការប្រើប្រាស់មិនបានត្រឹមត្រូវនូវផលិតផលដែលបានកំណត់ ។

ង- បម្រាមដែលចង្អុលបញ្ជាក់ពីគ្រោះថ្នាក់ដល់សុខភាពនៃការចាប់ផ្តើមប្រើប្រាស់ផលិតផល មុនដល់អាយុដែលណែនាំឱ្យប្រើប្រាស់បាន ហើយផលិតផលនេះអាចប្រើបានតែនៅពេលណាដែលមានការណែនាំពីបុគ្គលិកសុខាភិបាល ។

ច- ឃ្លាពន្យល់ថា ការបញ្ចុកដោយប្រើពែងមានអនាម័យច្រើនជាងការបំបៅដោយដប ។

ឆ- មិនត្រូវប្រើពាក្យបង្កប់ន័យថា ផលិតផលនេះប្រើសម្រាប់ជំនួសទឹកដោះម្តាយ ឬពាក្យប្រហាក់ប្រហែល ។

ជ- មិនត្រូវមានរូបថត រូបគំនូរ ឬក្រាហ្វិកតំណាង ក្រៅពីការបង្ហាញនូវវិធីរៀបចំផលិតផលដែលបានកំណត់នោះឡើយ ។

ឈ- ឃ្លាចង្អុលបញ្ជាក់ពីតម្លៃថវិកាសរុបសម្រាប់ចិញ្ចឹមទារកក្នុងរយៈពេល ៦ ខែ ។

**មាត្រា ១០.-**

ផលិតផលប្រហាក់ប្រហែលផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ មិនមាន់សារជាតិចិញ្ចឹម

គ្រប់គ្រាន់ តាមតម្រូវការរបស់ទារក និងកុមារ ត្រូវតែមានបម្រាមថា ផលិតផលនេះមិនមែនសម្រាប់ចិញ្ចឹមទារក និងកុមារឡើយ ។

**មាត្រា ១១.-**

នៅលើស្លាកដបបំបៅ ឬកញ្ចប់ ឬសម្បកផលិតផលដបបំបៅ ឬក្បាលដោះជ័រ ត្រូវសរសេរ ÷

១- ពាក្យថា គ្មានអ្វីប្រសើរជាងទឹកដោះម្តាយ ក្នុងការចិញ្ចឹមទារក និងកុមារតូចៗឡើយ ។

២- ការបញ្ចុកទារកដោយប្រើពែង មានសុវត្ថិភាពជាងការបំបៅដោយដប ។

៣- ការណែនាំអំពីរបៀបលាងសម្អាត និងស្ងោររំងាប់មេរោគដបបំបៅ និងក្បាលដោះជ័រឱ្យបានត្រឹមត្រូវ ។

៤- បម្រាមអំពីគ្រោះថ្នាក់ដល់សុខភាពដែលអាចបណ្តាលមកពីការប្រើប្រាស់ដបបំបៅ ជាពិសេសប្រសិនបើពុំបានស្ងោររំងាប់មេរោគអោយបានត្រឹមត្រូវ ។

៥- បម្រាមអំពីឥទ្ធិពលជាអវិជ្ជមាននៃការបំបៅដោយដប និងតម្រូវការអោយមានការអនុវត្តតាមការណែនាំអំពីការរៀបចំដោយប្រុងប្រយ័ត្ន ដើម្បីធានាថាទារកមិនធ្លាក់ខ្លួនឈឺ ។

៦- ឈ្មោះ និងអាស័យដ្ឋានរបស់ផលិតករ ឬអ្នកចែកចាយផលិតផល ឬភ្នាក់ងារតាមមូលដ្ឋាន។

៧- ការប្រើប្រាស់ក្បាលដោះជ័រនិងដបបំបៅ អាចធ្វើអោយរំខានដល់ការបំបៅកូនដោយទឹកដោះម្តាយ ។

**មាត្រា ១២.-**

នៅលើកំប៉ុង ឬស្លាកដែលបិទនៅលើកំប៉ុងទឹកដោះគោផ្អែមខាប់ ឬទឹកដោះគោគ្មានក្រែម ឬផលិតផលប្រហាក់ប្រហែល ត្រូវមានបម្រាមអោយបានច្បាស់ និងលេចធ្លោថា មិនត្រូវប្រើប្រាស់ផលិតផលនេះសម្រាប់ចិញ្ចឹមទារក និងកុមារតូចៗទេ ។

## ជំពូកទី ៥

## ការហាមឃាត់

**មាត្រា ១៣.-**

ក្នុងករណីគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ផលិតករ ឬអ្នកចែកចាយ មិនត្រូវធ្វើការផ្សព្វផ្សាយលើកកម្ពស់ការប្រើប្រាស់ផលិតផលសម្រាប់ចិញ្ចឹម ទារក និងកុមារតូចៗ ដូចមានចែងក្នុងអនុក្រឹត្យនេះ ដោយខ្លួនឯង ឬដោយការចាត់តាំងតំណាងរបស់ខ្លួននៅតាមកន្លែងជាក់លាក់ក្នុងមន្ទីរពេទ្យ ឬមណ្ឌលសុខភាព ឬទីកន្លែងផ្សេងទៀតឡើយ។ ខាងក្រោមនេះ គឺជាផ្នែកមួយ នៃសកម្មភាពផ្សព្វផ្សាយលើកកម្ពស់ការប្រើប្រាស់ដែលត្រូវហាមឃាត់ ÷

ក- ការឃោសនាពាណិជ្ជកម្ម។

ខ- ការប្រើប្រាស់មធ្យោបាយដែលជាល្បិចកលក្នុងគោលបំណងលក់ផលិតផល រួមមានការដាក់តាំងបង្ហាញពិសេស ប័ណ្ណបញ្ចុះតម្លៃភាគរយ ការលក់ថែម ការលក់ដោយផ្តល់កំរៃជើងសារ ការលក់បញ្ចុះតម្លៃ ការលក់ជឿ ការផ្តល់រង្វាន់លើកទឹកចិត្តដល់ការទិញ ការលក់តម្លៃពិសេស ឬការផ្តល់ជាអំណោយ។ ប៉ុន្តែកថាខណ្ឌ ខ នៃមាត្រានេះ មិនកម្រិតល័ក្ខខ័ណ្ឌទៅលើការកំណត់គោលនយោបាយតម្លៃ និងការអនុវត្តដែលមានគោលបំណងផ្តល់នូវផលិតផលដែលបានកំណត់នេះ ក្នុងតម្លៃកាន់តែទាបសម្រាប់រយៈពេលយូរនោះឡើយ។

គ- ការផ្តល់គំរូសាកផលិតផលដែលបានកំណត់មួយ ឬច្រើនដល់ជនណាម្នាក់ ។

ឃ- ការបរិច្ចាគ ឬចែកចាយសម្ភារៈឯកសារព័ត៌មាន ឬសម្ភារៈឯកសារអប់រំស្តីពីការចិញ្ចឹមទារក និងកុមារ ឬការអនុវត្តមុខងារអប់រំ ទាក់ទងទៅនឹងការចិញ្ចឹមទារក និងកុមារតូចៗអាចធ្វើទៅបានលុះត្រាតែផលិតករ និងអ្នកចែកចាយ អាចផ្តល់ព័ត៌មានស្តីពីផលិតផលដែលបានកំណត់ដល់បុគ្គលិកសុខាភិបាល ដែលព័ត៌មាននោះ កម្រិតល័ក្ខខ័ណ្ឌទៅលើបញ្ហាវិទ្យាសាស្ត្រ និងបញ្ហាជាក់ស្តែងទាក់ទងនឹងទិដ្ឋភាពបច្ចេកទេស និងវិធីសាស្ត្រប្រើប្រាស់ផលិតផលដែលបានកំណត់ ហើយស្របទៅតាមបញ្ញត្តិនៃមាត្រា ៦ នៃអនុក្រឹត្យនេះ ។

**មាត្រា ១៤.-**

ក្នុងករណីគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ផលិតករ ឬអ្នកចែកចាយ ទោះជាដោយខ្លួនឯងផ្ទាល់ ឬតាមរយៈជនណាម្នាក់ដែលជាតំណាងរបស់ខ្លួនក្តី មិនត្រូវ÷

ក- បរិច្ចាគ ឬចែកចាយដល់បុគ្គលិកសុខាភិបាល ឬមន្ទីរពេទ្យ ឬមណ្ឌលសុខភាព នូវសម្ភារៈ ឬគំរូសាកផលិតផលដែលបានកំណត់នោះឡើយ ។

ខ- បរិច្ចាគ ឬធ្វើការចែកចាយ ដល់មន្ទីរពេទ្យឬមណ្ឌលសុខភាព នូវគ្រឿងបរិក្ខារ សម្ភារៈ ឬឯកសារ ឬសេវាដែលបង្ហាញ ឬមានដាក់ឈ្មោះ ផ្លាកសញ្ញា សញ្ញាពាណិជ្ជកម្ម ឬសេចក្តីពិពណ៌នា របស់ផលិតករ អ្នកចែកចាយ ឬនៃផលិតផលដែលបានកំណត់ ដែលមានបង្ហាញ ឬផ្សព្វផ្សាយលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានកំណត់នេះឡើយ ។

គ- បរិច្ចាគ ឬចែកចាយ ដល់មន្ទីរពេទ្យ ឬមណ្ឌលសុខភាព នូវសម្ភារៈ ដូចជា ប៊ិច ប្រតិទិន ផ្ទាំងរូបភាព សៀវភៅសរសេរ តារាងតាមដានការលូតលាស់ និងប្រដាប់ក្មេងលេង ដែលមានបង្ហាញ ឬផ្សព្វផ្សាយលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានកំណត់នេះឡើយ ។

ឃ- ផ្តល់ជាអំណោយ វិភាគទាន ឬផលប្រយោជន៍អ្វីមួយ ដល់បុគ្គលិកសុខាភិបាល ឬ សមាជិកបុគ្គលិកសុខាភិបាល ដែលធ្វើការងារក្នុងផ្នែកសុខភាពមាតា និងទារកឡើយ ។

ង- ឧបត្ថម្ភដល់ពិធីផ្សេងៗ កម្មវិធីល្បែងកំសាន្ត បណ្តាញទូរស័ព្ទសម្រាប់ការផ្តល់ប្រឹក្សា ឬ យុទ្ធនាការដែល

មានផ្ដោតទៅលើស្ត្រីមានផ្ទៃពោះ និងស្ត្រីកំពុងបំបៅដោះកូន ឪពុក-ម្ដាយរបស់ទារក និងកុមារ ឬសមាជិកគ្រួសារ និងមិនត្រូវឧបត្ថម្ភដល់ពិធីផ្សេងៗ កម្មវិធីល្បែងកំសាន្ត បណ្ដាញទូរស័ព្ទសម្រាប់ផ្ដល់ប្រឹក្សា ឬយុទ្ធនាការ ដែលពាក់ព័ន្ធទៅនឹងសុខភាពបន្តពូជ ការមានផ្ទៃពោះ ការសម្រាលកូន ការចិញ្ចឹមទារក និងកុមារ ឬប្រធានបទណាមួយដែលពាក់ព័ន្ធឡើយ ។

ច- ផ្ដល់អាហារូបករណ៍ដោយផ្ទាល់ ឬដោយប្រយោល ការឧបត្ថម្ភដល់ការស្រាវជ្រាវ ឬផ្ដល់ថវិកាសម្រាប់ការប្រជុំ សិក្ខាសាលា វគ្គអប់រំបន្ត ឬសន្និសីទ ដោយគ្មានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសុខាភិបាលឡើយ ។

ឆ- ផ្ដល់ ឬឱ្យប្រាក់ខែដល់អ្នកតំណាងវិជ្ជាជីវៈផ្ដល់សេវា អ្នកមានជំនាញថែទាំទារក ឬបុគ្គលិកដែលមានជំនាញប្រហាក់ប្រហែល នៅតាមមន្ទីរពេទ្យ ឬមណ្ឌលសុខភាព ។

ជ- ដាក់បញ្ចូលទំហំនៃការលក់ដូរផលិតផលដែលបានកំណត់ នៅពេលទូទាត់ប្រាក់បំណាច់ដល់និយោជិក និងមិនត្រូវកំណត់ចំនួនកូតាសម្រាប់ការលក់ផលិតផលដែលបានកំណត់នោះឡើយ ។

**មាត្រា ១៥.-**

ក្នុងករណីគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល គ្រប់គ្រឹះស្ថានសុខភាព ទាំងសាធារណៈ និងទាំងឯកជនរួមទាំងបុគ្គលិកសុខាភិបាល ដែលបម្រើការងារផ្នែកសុខភាពមាតា និងទារកផង មិនត្រូវ ÷

ក- ទទួលយកអំណោយ វិភាគទាន ឬផលប្រយោជន៍ផ្សេងៗ ថវិកា ឬវត្ថុមានតម្លៃអ្វីមួយពីផលិតករ ឬអ្នកចែកចាយ ឬពីបុគ្គលណាម្នាក់ដែលជាតំណាងផលិតករឡើយ ។

ខ- ធ្វើការបង្ហាញអំពីវិធីប្រើប្រាស់ទឹកដោះគោម្សៅផ្សំតាមរូបមន្តឡើយ លើកលែងតែស្ត្រីជាមាតា ឬសមាជិកគ្រួសារ ដែលស្ថិតក្នុងករណីពិសេសចាំបាច់បំផុត ហើយ ក្នុងករណីបែបនេះ ត្រូវធ្វើការពន្យល់ឱ្យបានច្បាស់អំពីគ្រោះថ្នាក់ ដែលបណ្ដាលមកពីការប្រើប្រាស់ទឹកដោះគោម្សៅផ្សំតាមរូបមន្ត រួមទាំងព័ត៌មានផ្សេងទៀត ដូចមានចែងក្នុងមាត្រា ៦ នៃអនុក្រឹត្យនេះឡើយ ។

គ- ទទួលយក ឬផ្ដល់គំរូសាក ឬផ្គត់ផ្គង់ផលិតផលដែលបានកំណត់ ដល់បុគ្គលណាម្នាក់ឡើយ ។

ឃ- ធ្វើការវាយតម្លៃវិជ្ជាជីវៈ ចុះសិក្សាស្រាវជ្រាវ ឬអនុវត្តសកម្មភាពផ្សេងទៀត នៅតាមមន្ទីរពេទ្យឬមណ្ឌលសុខភាព ទាក់ទងនឹងផលិតផលដូចដែលបានកំណត់ខាងលើ ។

**មាត្រា ១៦.-**

ផលិតករ ឬអ្នកចែកចាយផលិតផល សម្រាប់ចិញ្ចឹមទារក និងកុមារ អាចបរិច្ចាគ គ្រឿងបរិក្ខារ និងសម្ភារៈ ដល់គ្រប់គ្រឹះស្ថានសុខភាព ទាំងសាធារណៈ និងទាំងឯកជន តាមការស្នើសុំជាលាយល័ក្ខណ៍អក្សររបស់សាមីអង្គភាព ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

# ជំពូកទី ៦
# សមត្ថកិច្ចគ្រប់គ្រង និងត្រួតពិនិត្យ

**មាត្រា ១៧.-**

ក្រសួងសុខាភិបាលជាសមត្ថកិច្ចទទួលខុសត្រូវ សហការ សម្របសម្រួលការអនុវត្តភារកិច្ចចិញ្ចឹមទារក និងកុមារតូចៗអោយមានប្រសិទ្ធភាពជាមួយក្រសួងពាក់ព័ន្ធតាមសមត្ថកិច្ចរៀងៗខ្លួនដូចខាងក្រោម ÷

ក- ផ្តល់យោបល់ដល់គណៈកម្មាធិការជាតិអាហារូបត្ថម្ភ អំពីគោលនយោបាយជាតិសម្រាប់ការលើកកម្ពស់ និងទិសដៅយុទ្ធសាស្ត្រជាតិគាំពារការបំបៅកូនដោយទឹកដោះម្តាយ ។

ខ- ផ្តល់យោបល់ជូនអំពីអាហារូបត្ថម្ភស្តីអំពី ÷

- ការរៀបចំយុទ្ធសាស្ត្រជាតិ សម្រាប់រៀបចំកម្មវិធីអប់រំសាធារណៈ និងសម្ភារៈសម្រាប់អប់រំ ។
- លើកកម្ពស់ការបំបៅកូនដោយទឹកដោះម្តាយ
- សម្ភារៈឬឯកសារអប់រំ និងព័ត៌មានផ្សព្វផ្សាយ ទាក់ទងនឹងប្រធានបទស្តីពីការចិញ្ចឹមទារក និងកុមារតូចៗ
- ការបន្តអប់រំដល់បុគ្គលិកសុខាភិបាល ពីរបៀបគ្រប់គ្រងទឹកដោះម្តាយ
- កម្មវិធីសិក្សាស្តីពីរបៀបគ្រប់គ្រងទឹកដោះម្តាយសម្រាប់និស្សិតពេទ្យ ។

គ- ធ្វើការពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលពាក់ព័ន្ធក្នុងវិស័យសុខុមាលភាពកុមារ និងការអភិវឌ្ឍអាហារូបត្ថម្ភសម្រាប់កុមារ ឬការការពារទារក និងកុមារតូចៗ ។

ឃ- ធានាធ្វើយ៉ាងណាអោយមានការផ្សព្វផ្សាយអោយបានទូលំទូលាយនូវច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយ និងការប្រកាសផ្សាយនៅទូទាំងប្រទេស ។

ង- ពិនិត្យលើរបាយការណ៍ ទាក់ទងនឹងការបំពានច្បាប់ ឬបញ្ហាផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងការអនុវត្តន៍អនុក្រឹត្យនេះ និងច្បាប់ពាក់ព័ន្ធជាធរមាន ។

ច- ធ្វើការផ្សព្វផ្សាយនូវសេចក្តីណែនាំដល់ក្រុមមន្ត្រីត្រួតពិនិត្យដើម្បីលើកឡើងនូវករណីទាំងឡាយណា ដែលបានប្រព្រឹត្តខុសពីអនុក្រឹត្យនេះ ឬប្រព្រឹត្តបំពាននឹងច្បាប់ជាធរមាន ។

ឆ- ពិចារណាពីភាពចាំបាច់ណាមួយសម្រាប់ក្រសួងសុខាភិបាល និងក្រសួងពាណិជ្ជកម្ម ធ្វើការអនុវត្តយ៉ាងពេញលេញនូវបទប្បញ្ញត្តិនៃច្បាប់នានា ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ជ- ស្នើ និងបញ្ជូននូវវត្ថុធាតុជាអាហារូបត្ថម្ភ ទៅមន្ទីរពិសោធន៍ ឬធ្វើតេស្តតាមការចំបាច់ ។

ឈ- ស្វែងរកថវិកា និងជំនួយពីប្រភពអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ផ្តល់ជំនួយនានា ។

ញ- បំពេញតួនាទី និងសមត្ថកិច្ចចាំបាច់នានា ដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព ផលិតផល ទំនិញ និងសេវា ។

ដ- មានសិទ្ធិចេញសេចក្តីសម្រេចចាំបាច់ ទាក់ទងនឹងការអនុវត្តន៍អនុក្រឹត្យនេះ និងច្បាប់ពាក់ព័ន្ធ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ឋ- កំណត់វិធានការជាតិ ដើម្បីអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន ដែលកំណត់ដោយអនុក្រឹត្យនេះ និងធ្វើការត្រួតពិនិត្យលើផែនការសកម្មភាពចាំបាច់ទាំងឡាយ ។

ឌ- បំពេញភារកិច្ចពាក់ព័ន្ធដទៃទៀត ដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ១៨.-**

ការអនុវត្តទោសប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយលក់ផលិតផលសំរាប់ចិញ្ចឹម ទារក និងកុមារ ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពផលិតផល ទំនិញ និងសេវា ឬតាមច្បាប់ផ្សេងៗទៀតជាធរមាន។

**មាត្រា ១៩.-**

អាជ្ញាធរមានសមត្ថកិច្ចក្នុងការបំពេញភារកិច្ចរបស់ខ្លួន ត្រូវគោរពតាមនីតិវិធី ដែលបានកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពផលិតផល ទំនិញ និងសេវា និងតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

**មាត្រា ២០.-**

ក្នុងរយៈពេលប្រាំមួយ (៦) ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ផលិតករ ឬអ្នកចែកចាយ ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ត្រូវបំពេញបែបបទ ដែលកំណត់ដោយក្រសួងសុខាភិបាលឱ្យបានត្រឹមត្រូវ តាមបញ្ញត្តិជាធរមាន ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ២១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ គ្រប់អភិបាលខេត្ត ក្រុង ត្រូវអនុវត្តអនុក្រឹត្យចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ២២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :១៣៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ។
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ,បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៤/០០២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ។
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ,បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# <u>សំរេច</u>

**<u>មាត្រា១</u>** : ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៣០៥.១៣០.០០០រៀល (បីរយប្រាំលានមួយរយសាមសិបពាន់រៀលគត់) ពីជំពូក ១២ (ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការអង្គការសាធារណៈរដ្ឋបាល) ជំពូក ៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច) ជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌) និងជំពូក ៣២ (អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ វិភាគទានអោយអង្គការអន្តរជាតិនានា) មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។

**<u>មាត្រា២</u>** : ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់បំពេញខ្វះចំណាយប្រេងឥន្ធនៈ និង ប្រេងរំអិល សោហ៊ុយរបសកកម្ម និងសោហ៊ុយស្នាក់នៅ ដែលគ្រោងខ្វះក្នុងឆ្នាំ ២០០៥ ។

**<u>មាត្រា៣</u>** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ-ឯកសារ

**បានយកសេចក្តីជំរាបជូន**
**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ៨៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** តែងតាំងលោកស្រី សូរ ដារ៉ា ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៩៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

១៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **JUNG YOUNG CHOOL** ពាណិជ្ជករកូរ៉េ ដែលបានជួយឧបត្ថម្ភ ដល់កងពលតូចទ័ពពិសេស ឆ័ត្រយោង ៩១១ នូវសម្ភារៈហ្វឹកហ្វឺន **SCUBA** មានថ្លៃជាទឹកប្រាក់ ចំនួន ១១.០០០ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៨៩៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## សម្រេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនលោក **JUN BYUNG MAN** អនុប្រធានសមាគមពាណិជ្ជករកូរ៉េ ដែលមានស្នាដៃល្អ ក្នុងការធ្វើសហប្រតិបត្តិការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាង ដល់កងពលតូចទ័ពពិសេស ឆ័ត្រយោង ៩១១ តាំងពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០៥ ។

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៣០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលរាជធានីភ្នំពេញ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនថ្នាក់ដឹកនាំសាលាក្រុងភ្នំពេញ ចំនួន ០២រូប ដែលមានស្នាដៃល្អ ក្នុងការកសាងនិងអភិវឌ្ឍន៍រាជធានីភ្នំពេញ លើវិស័យអប់រំ គមនាគមន៍ និងព្រះពុទ្ធសាសនា ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :**

- ឯកឧត្តម **កែប ជុតិមា** អភិបាលរាជធានីភ្នំពេញ

**ខ.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :**

- ឯកឧត្តម **ម៉ប់ សារិន** អភិបាលរងរាជធានីភ្នំពេញ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ ១១ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៨ សហវ

## សារាចរណែនាំ

## ស្តីពីការបិទបញ្ជីចំណូល ចំណាយ

## និងធ្វើរបាយការណ៍បូកសរុបទូទាត់ថវិកាខេត្ត ក្រុង ឆ្នាំ ២០០៥

យោងមាត្រា ១២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ និងប្រការ ៣២ ប្រការ ៣៣ នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ បានកំណត់ថា ថវិកាខេត្ត ក្រុងត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិទូទៅ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដូច្នេះ ដើម្បីធានាអោយការបិទបញ្ជីចំណូល ចំណាយ និងធ្វើរបាយការណ៍បូកសរុបសំរេចទូទាត់ថវិកាខេត្ត ក្រុងប្រចាំឆ្នាំ ២០០៥ ប្រព្រឹត្តទៅបានត្រឹមត្រូវ និងទាន់ពេលវេលានោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីនីតិវិធីបច្ចេកទេសដូចតទៅ ៖

១. អភិបាលខេត្ត ក្រុងដែលជាអាណាប័កដើមខ្សែ ត្រូវខិតខំជំរុញចំណូលសារពើពន្ធ និងប្រមូលចំណូលមិនមែនសារពើពន្ធ ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន បង់ចូលថវិកាខេត្ត ក្រុងទាំងអស់យ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ។ ប្រសិនបើមានការយឺតយ៉ាវក្រោយថ្ងៃកំណត់នេះ រតនាគារខេត្ត ក្រុង ត្រូវកត់ត្រាចូលជាចំណូលថវិកាខេត្ត ក្រុងសំរាប់ឆ្នាំ ២០០៦ ។

២. ការស្នើសុំថវិកាឧបត្ថម្ភតុល្យភាព ក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុងទាំងអស់ ត្រូវបញ្ជូនសំណុំលិខិតស្នើ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៥ ។

៣. ការធ្វើនិយ័តភាពឥណទានផ្ទៃក្នុងជំពូក ក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុងទាំងអស់ ត្រូវបញ្ជូនសំណុំលិខិតស្នើសុំមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ក្រុង យ៉ាងយូរត្រឹមថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៥ ។ ដោយឡែកការធ្វើនិយ័តភាពឥណទានដែលពាក់ព័ន្ធដល់ការសុំអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុងទាំងអស់ត្រូវបញ្ជូនសំណុំលិខិតស្នើសុំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៥ ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ ៈ ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ ៈ ៨៥៥-២៣ ៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

៤. រតនាគារខេត្ត ក្រុង ត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់នៅម៉ោង ១៧ និង៣០នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ។ ដូច្នេះក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុង ត្រូវរួសរាន់ប្រមូលសក្ខីប័ត្រ និង លិខិតយុត្តិការ ដើម្បីធ្វើអាណត្តិ (ទាំងអាណត្តិទូទាត់ត្រង់ ទាំងអាណត្តិទូទាត់រដ្ឋទេយ្យបុរេប្រទាន) បញ្ជូនទៅថ្នាក់ទីស្តីការមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ រួចដាក់ជូនឯកឧត្តមអភិបាលខេត្ត ក្រុងចុះហត្ថលេខា និង បញ្ជូនទៅរតនាគារខេត្ត ក្រុងអោយបានមុនម៉ោង ១៧ និង៣០នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ។

៥. នៅចុងថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ រតនាគារខេត្ត ក្រុង ត្រូវដំណើរការផ្ទេរសមតុល្យគណនីចំណូល ចំណាយរបស់សាលាខេត្ត ក្រុង ចូលទៅក្នុងគណនីលទ្ធផលនៃការិយបរិច្ឆេទ ។ ប្រសិនបើមានអតិរេក នោះសាលាខេត្ត ក្រុងត្រូវធ្វើសលាកប័ត្រចំណូលបង់ចូលថវិការដ្ឋឆ្នាំ ២០០៥ ជាបន្ទាន់ ក្នុងករណីមានការយឺតយ៉ាវស្ថិតនៅ ចន្លោះពីថ្ងៃទី ០១ ខែ មករា ដល់ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៦ នោះ កាលបរិច្ឆេទនៃការបង់ក៏ត្រូវចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ដែរ ។ ផ្ទុយទៅវិញ ប្រសិនបើហួសកាលកំណត់ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៦ ហើយ សាលាខេត្ត ក្រុង នៅតែពុំទាន់បានបង់ទេនោះ គឺរតនាគារខេត្ត ក្រុងត្រូវម្ចាស់ការផ្ទេរដោយស្វ័យប្រវត្តិចូលជាចំណូលថវិការដ្ឋ ហើយត្រូវជូនដំណឹងទៅសាលាខេត្ត ក្រុងអោយបានជ្រាប ។ កាលបរិច្ឆេទនៃការផ្ទេរនេះ ក៏ត្រូវចាត់ទុកជាកិច្ចប្រតិបត្តិការថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ដែរ ។

៦. កិច្ចប្រតិបត្តិការនិយ័តភាវូបនីយកម្មរបស់រតនាគារ សំរាប់ថវិកាខេត្ត ក្រុង ឆ្នាំ ២០០៥ ត្រូវបន្តរហូតដល់ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៦ ។ កិច្ចប្រតិបត្តិការនេះ ត្រូវបានពិនិត្យកត់ត្រាជាលេខនាបន្ថែមនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលទាក់ទងទៅនឹង ៖

- ការកត់ត្រាជាស្ថាពរនៃចំណូល ឬនៃចំណាយ ដែលបានពិនិត្យកត់ត្រាជាលេខនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ជាអាទិ៍ ចូលគណនីកត់ត្រាបណ្តោះអាសន្ន ។
- អាណត្តិនិយ័តភាវូបនីយកម្ម ដែលទាក់ទងដល់ចំណាយដែលបានទូទាត់ដោយរដ្ឋទេយ្យបុរេប្រទានមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ។
- ការកែប្រែលេខនាខុស ។

៧. ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៦ តទៅ រាល់កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាខេត្ត ក្រុងឆ្នាំថ្មី ត្រូវកត់ត្រាចូលក្នុងគណនីថវិកាខេត្ត ក្រុងឆ្នាំ ២០០៦ ។

៨. ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៦ រតនាគារខេត្ត ក្រុង និងក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុង ត្រូវដំណើរការបូកសរុបនិងផ្ទៀងផ្ទាត់អំពីការអនុវត្តចំណូល ចំណាយថវិកាខេត្ត ក្រុង ឆ្នាំ ២០០៥ ដោយរតនាគារខេត្ត ក្រុងត្រូវបង្កើតតារាងតុល្យភាពគណនីប្រចាំឆ្នាំ និងក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុងត្រូវធ្វើតារាងបូកសរុបចំណូល ចំណាយថវិកាខេត្ត ក្រុងតាមមាតិកាថវិកា រួចធ្វើកំណត់បង្ហាញដាក់ជូនឯកឧត្តមអភិបាលខេត្ត ក្រុងពិនិត្យសំរេចនិងចុះហត្ថលេខា។ អភិបាលខេត្ត ក្រុងត្រូវធ្វើលិខិត

បញ្ជូនតារាងតុល្យភាពគណនីប្រចាំឆ្នាំ តារាងបូកសរុបចំណូល ចំណាយ និងកំណត់បង្ហាញខាងលើទៅក្រសួងមហាផ្ទៃចំនួន ០១ច្បាប់ និងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ០២ច្បាប់ អោយបានមុនថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៦ ដើម្បីនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការបូកសរុប និងរៀបចំនូវរបាយការណ៍សំរេចទូទាត់ថវិកាខេត្ត ក្រុងរួមមួយ ដើម្បីដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។

អភិបាលខេត្ត ក្រុង ត្រូវយកចិត្តទុកដាក់អនុវត្តអោយបានតាមការកំណត់ដូចខាងលើ ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានលទ្ធភាពធ្វើការបូកសរុប រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសំរេច និងរដ្ឋសភា ព្រឹទ្ធសភាពិនិត្យអនុម័តអោយបានទាន់ពេលវេលា ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**

***ចំលងជូន:***

- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងមហាផ្ទៃ*
- *ធនាគារជាតិ*
- *សាលាខេត្ត ក្រុង*
- *មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ក្រុង*
- *ធនាគារខេត្ត ក្រុង*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

លេខកូដ............

# តារាងបូកសរុបចំណុលថវិកាខេត្ត ក្រុង
# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥

តារាងឧបសម្ព័ន្ធ១

| ជំពូក | ប្រការ | កថាខណ្ឌ | វាក្យខណ្ឌ | បរិយាយ ចំណាត់ថ្នាក់ចំណូល ១ | ច្បាប់ ហិរញ្ញវត្ថុដើមឆ្នាំ ២ | អនុវត្ត ជាក់ស្តែង ៣ | សមាមាត្រ ប្រៀបធៀប ៤-៣ / ២ | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | សរុបរួម | | | | |

| | | | |
|---|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា |
| អភិបាលខេត្ត ក្រុង | ប្រធានរតនាគារខេត្ត ក្រុង | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អ្នកធ្វើតារាង |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

លេខកូដ............

# តារាងបូកសរុបចំណាយថវិកាខេត្ត ក្រុង
# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥

តារាងឧបសម្ព័ន្ធ២

| ជំពូក ប្រការ កថាខណ្ឌ អនុកថាខណ្ឌ | បរិយាយ ចំណាត់ថ្នាក់ចំណាយ ១ | ច្បាប់ ហិរញ្ញវត្ថុដើមឆ្នាំ ២ | ឥណទាន អនុញ្ញាត ៣ | អនុវត្ត ជាក់ស្តែង ៤ | សមាមាត្រ ប្រៀបធៀប ៥=៤ / ៣ | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | សរុបរួម | | | | | |

| | | | |
|---|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា |
| អភិបាលខេត្ត ក្រុង | ប្រធានរតនាគារខេត្ត ក្រុង | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អ្នកធ្វើតារាង |

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ ៖ ០០៧ សរ.ស

ភ្នំពេញ, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥

# សារាចរណែនាំ

## ស្តីពី

## ការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

អនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០២បប ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ បានតំរូវឱ្យគ្រប់ក្រសួង-ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន និង ខេត្ត-ក្រុង អនុវត្ត និងធានានូវការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋឱ្យបានម៉ត់ចត់ គង់វង្ស និង ប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាព នៃសេដ្ឋកិច្ច ស្របតាមគោលការណ៍ហិរញ្ញវត្ថុជាធរមាន ។ ផ្អែកតាមបទបញ្ជានេះ ក្រសួងមហាផ្ទៃ ធ្វើការណែនាំដល់គ្រប់ បណ្តាអង្គភាពក្រោមឱវាទ លើការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋដល់អង្គភាពនីមួយៗ ដែលកំពុងគ្រប់គ្រងថែរក្សា ប្រើប្រាស់ ។ ដូចនេះ ដើម្បីពង្រឹងលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋឱ្យបានម៉ឺងម៉ាត់ស្របតាម នីតិវិធីហិរញ្ញវត្ថុ ចៀសវាងការចាត់ចែង និង ប្រើប្រាស់ដោយរំលោភបំពានលើផ្លូវច្បាប់ ដែលបណ្តាលឱ្យខូចខាត ឬ បាត់បង់ទ្រព្យសម្បត្តិរបស់រដ្ឋជាយថាហេតុ ព្រមទាំងប៉ះពាល់ដល់ផលប្រយោជន៍សេដ្ឋកិច្ចជាតិ ។

ដើម្បីធានាឱ្យការប្រព្រឹត្តទៅមានតម្លាភាព ក្រសួងមហាផ្ទៃបានដាក់ចេញនូវវិធានការណែនាំមួយចំនួនដល់គ្រប់បណ្តាអង្គភាព ទាំងផ្នែករដ្ឋបាលស៊ីវិល និងផ្នែកសន្តិសុខសាធារណៈទាំងអស់ ក្រោមឱវាទក្រសួងដូចតទៅ :

### I. គោលការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ :

ទ្រព្យសម្បត្តិទាំងឡាយដែលបានកំណត់ជាទ្រព្យសម្បត្តិរដ្ឋ ដូចមានចែងក្នុងមាត្រា ៥៨ ជំពូក៥ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ហើយបាន និង កំពុងស្ថិតនៅក្នុងដែនកាន់កាប់របស់អាជ្ញាធរ និង សមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ដែលត្រូវបានអង្គភាព ស្ថាប័ននីមួយៗ កំពុងគ្រប់គ្រង ថែរក្សា ប្រើប្រាស់ ។ រាល់ទ្រព្យសម្បត្តិទាំងអស់នោះត្រូវបានច្បាប់ កំណត់ជាទ្រព្យសម្បត្តិរបស់រដ្ឋដោយច្បាប់ រួមមានទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និង ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ។

#### ១. ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ :

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ មាន ០២ ផ្នែកគឺ : ផ្នែកអចលនទ្រព្យ និង ចលនទ្រព្យ ។

#### ក. អចលនទ្រព្យ :

ទីតាំងដីសំណង់-អគារ ការិយាល័យ ស្ថិតនៅតាមបណ្តាអង្គភាពនីមួយៗ កំពុងប្រើប្រាស់ និង ថែរក្សាត្រូវបានកត់ត្រាចុះក្នុងបញ្ជីសារពើភ័ណ្ឌរបស់រដ្ឋ ផ្ញើជូនក្រសួងមហាផ្ទៃ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយក្តីមិនទាន់បានកត់ត្រាក្តី ជាដីទំនេរមិនទាន់បានប្រើប្រាស់ក្តី ដី-អគារបានប្រគល់ឱ្យឯកជនជួលកាន់កាប់ធ្វើអាជីវកម្ម ✓

ហើយក្តី ឬ ដីសំណង់អគារ ដែលមន្ត្រី ឬ ប្រជាពលរដ្ឋបានយកមកស្នាក់នៅបណ្តោះអាសន្នក្តី រាល់ទីតាំងដី-អគារទាំងនេះត្រូវកំណត់ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ហើយរដ្ឋបានផ្តល់សិទ្ធិជូននីតិបុគ្គលសាធារណៈទាំងឡាយតំណាងឱ្យសាមីក្រសួង-ស្ថាប័ន-អាជ្ញាធរដែនដី អង្គភាពរបស់រដ្ឋនីមួយៗ សំរាប់ទទួលខុសត្រូវលើការធ្វើប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុរបស់រដ្ឋ-ការធ្វើសារពើភ័ណ្ឌ-ការលប់ចេញពីបញ្ជីសារពើភ័ណ្ឌ ព្រមទាំងការចុះហត្ថលេខាលើលិខិតបទដ្ឋានផ្សេងៗ ស្របតាមគោលការណ៍នៃច្បាប់ ។ ចំពោះនិតិបុគ្គលសាធារណៈអាចមានសិទ្ធិប្រតិបត្តិទៅបាន លុះត្រាតែមានការប្រគល់សិទ្ធិជាផ្លូវការពីរាជរដ្ឋាភិបាល ឬរដ្ឋមន្ត្រីដែលទទួលខុសត្រូវលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋក្នុងក្រសួង ។

**ខ. ចលនទ្រព្យរបស់រដ្ឋ : រួមមាន ០៣ ប្រភេទ :**

-សំភារៈបរិក្ខា-ឧស្សាហកម្ម (ឧទាហរណ៍ម៉ាស៊ីនភ្លើង 100KVA ម៉ាស៊ីនផលិត ឬ កែច្នៃធុនធ្ងន់)

-រថយន្ត និង គ្រឿងចក្រ (ឧទាហរណ៍ រថយន្តដឹកជញ្ជូន រថយន្តស៊ីរ៉ែន រថយន្តអគ្គីភ័យ រថយន្តទេសចរណ៍ ម៉ូតូ អូប័រ កាណូត ត្រាក់ទ័រ ម៉ាស៊ីនភ្លើងធន់មធ្យម ។ល។)

-សំភារៈសង្ហារឹម (ឧទាហរណ៍ កុំព្យូទ័រ ម៉ាស៊ីនហ្វូតូកូពី កាមរ៉ាថត ទូរទស្សន៍ តុ ទូ កៅអី វិទ្យុទាក់ទងគ្រប់ធុន ។ល។

រាល់សំភារៈខាងលើ ទោះបីបានមកពីក្រសួងផ្តល់ សប្បុរសជនផ្តល់ ជាជំនួយអង្គការជាតិ-អន្តរជាតិក្នុង ឬក្រៅប្រទេសផ្តល់ ត្រូវបានចុះក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ តាមការណែនាំរបស់ជំនាញ ដោយថែរក្សាប្រើប្រាស់ និងចាត់ចែង ទៅតាមប្រព័ន្ធច្បាប់របស់រដ្ឋ ដែលបានកំណត់ ។

**គ. ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ :**

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋកំពុងស្ថិតនៅក្នុងដែនអាជ្ញាធរសមត្ថកិច្ច គ្រប់គ្រងទាំងនោះ រួមមានបឹងធម្មជាតិ ច្រាំងទន្លេ ស្ទឹង ព្រែក ដីកោះ ផ្លូវលំ ផ្លូវជាតិ ផ្លូវដែក ឆ្នេរ សមុទ្រ ព្រៃឈើ ភ្នំ សួនច្បារ ឧទ្យានសាធារណៈ ដីចំណីថ្នល់ ដីទំនេរ កំពង់ផែ ព្រលានយន្តហោះ ធនធានរ៉ែធម្មជាតិ ។ល។ ទ្រព្យទាំងនេះត្រូវបានកំណត់ដោយ ច្បាប់ ។

## II. វិធានការសំរាប់អនុវត្ត :

ចាប់ពីថ្ងៃនេះតទៅ ត្រូវផ្អាករាល់ការលក់ ផ្ទេរ ដោះដូរ ជួល ឬ ផ្តល់ឱ្យជាសម្បទាននូវទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និង នីតិបុគ្គល សាធារណៈទាំងឡាយលើកលែងតែមានច្បាប់ អនុក្រឹត្យ និង លិខិតបទដ្ឋានសំរាប់អនុវត្តត្រឹមត្រូវ ។

-ច្បាប់ស្តីពីសម្បទាន (សំរាប់ឱ្យវិស័យឯកជន ចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធ) និង លិខិតបទដ្ឋានសំរាប់អនុវត្តច្បាប់នេះ ។

-អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច

-អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ ...

-អនុក្រឹត្យស្ដីពីនីតិវិធីនៃការលក់ ការគ្រប់គ្រងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈស្របតាមមាត្រា ១៥ និង ១៧ នៃច្បាប់ភូមិបាល ។

រាប់ចូលក្នុងសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ (ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ) មាន :

**ក. ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ :**

-ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចត្រូវបានលក់ ផ្ទេរ ជួល ឬ ផ្ដល់ឱ្យជាសម្បទានផ្សេងៗបានឡើយ លុះត្រាតែទ្រព្យសម្បត្តិសាធារណៈទាំងនោះ ត្រូវបានកំណត់ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈស្របតាមបទបញ្ញត្តិច្បាប់ ។ ពុំអាចមានបុគ្គលណាមួយមានសិទ្ធិកាន់កាប់ ប្រើប្រាស់ លក់ ដូរ ជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋបានជាដាច់ខាត ។

**ខ. ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ :**

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទាំងអស់កំពុងស្ថិតនៅក្នុងការប្រើប្រាស់ ថែរក្សា របស់អង្គភាពក្រោមឱវាទក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលស៊ីវិលមាន : (ឧទាហរណ៍ ដី អគារ សំណង់ សាលាខេត្ត-ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ ភូមិ និង សំណង់រដ្ឋបាលមួយចំនួនទៀត ។ល។

ផ្នែកសន្តិសុខសាធារណៈមាន : ដី អគារ សំណង់ ស្នងការដ្ឋាននគរបាលខេត្ត-ក្រុង អធិការដ្ឋាន នគរបាលខណ្ឌ-ស្រុក ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ និងទីតាំង-អគារ ដែលកំពុងឈរជើងបំពេញការងារ ដោយឡែកមួយចំនួនទៀត ។ល។ ទ្រព្យទាំងនេះត្រូវបានកំណត់ជាទ្រព្យសម្បត្តិរដ្ឋដោយច្បាប់ ។

**គ. វិធានការម៉ឺងម៉ាត់ :**

ល័ក្ខខ័ណ្ឌទាំងឡាយនិង នីតិវិធីនៃការលក់ ដោះដូរ ផ្ទេរ ជួល និងការគ្រប់គ្រងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈដែលកំណត់ដោយអនុក្រឹត្យ ។ គ្មានការលក់ ដោះដូរ ផ្ទេរ ជួល ទ្រព្យសម្បត្តិរបស់រដ្ឋមួយណាអាចប្រព្រឹត្តិទៅបាន ដោយមិនបំពេញតាមនីតិវិធី ផ្អែកតាមអនុក្រឹត្យបានឡើយ ។ ហើយគ្មានការចាប់ ឬ កាត់យកដីរបស់អង្គភាពរដ្ឋ ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ តាមទំនើងចិត្តណាមួយអាចកើតមានឡើងជាដាច់ខាត ។

**III. ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈស្របតាមបទបញ្ញត្តិនៃច្បាប់ហិរញ្ញវត្ថុ :**

ចំពោះឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវបានអនុញ្ញាតដោយមាត្រា ៨១ នៃច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ គឺត្រូវអនុវត្តឱ្យបានត្រឹមត្រូវ ប្រកបដោយតម្លាភាព និង ម៉ឺងម៉ាត់បំផុតតាមការកំណត់នៃបទបញ្ញត្តិច្បាប់ និង លិខិតបទដ្ឋានជាធរមាន រួមមានជាអាទិ៍ អនុក្រឹត្យលេខ ៣៨អនក្រ ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ១៩៩៥ និង អនុក្រឹត្យលេខ ៤៩ អនក្រ បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ និង បទបញ្ជាស្ដីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ លេខ ៣០ បប ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ១៩៩៧ ព្រមទាំង សារាចរស្ដីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋលេខ ០០១ សរ ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ ១៩៩៩ របស់ក្រសួងមហាផ្ទៃ ។

## IV. ការគ្រប់គ្រងសម្បទាន :

ក្នុងរយៈពេលរង់ចាំ **ច្បាប់ស្តីពីសម្បទាន** ចាប់ពីពេលនេះតទៅ ការផ្តល់សម្បទាននានា ត្រូវអនុវត្តនីតិវិធី នៃការដេញថ្លៃជាសាធារណៈ ប្រកបដោយតម្លាភាព លើមូលដ្ឋាននៃសៀវភៅបន្ទុកត្រឹមត្រូវ និង ច្បាស់លាស់ ។

## V. ការប្រគល់សិទ្ធិ :

រាល់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ ស្ថិតនៅក្នុងដែនអាជ្ញាធរ និង សមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ដែលបាននឹងកំពុងគ្រប់គ្រង ប្រើប្រាស់ និង ថែរក្សា រដ្ឋប្រគល់សិទ្ធិឱ្យតែគ្រប់គ្រងថែរក្សា និង ប្រើប្រាស់ទៅលើវិស័យនានារបស់ រដ្ឋដែលបំរើឱ្យផលប្រយោជន៍សាធារណៈ និង សង្គមតែប៉ុណ្ណោះ ។ ហើយត្រូវហាមឃាត់ដាច់ខាតនូវ ការលក់ ដូរ ផ្ទេរ ជួល ទ្រព្យសម្បត្តិរដ្ឋ ខុសគោលការណ៍នៃច្បាប់ ក្នុងករណីមានការលក់ ដូរ ផ្ទេរ ជួល សម្បទាននូវទ្រព្យសម្បត្តិរដ្ឋណាមួយដែលអាចប្រព្រឹត្តទៅបាន លុះត្រាតែអនុវត្តតាមនីតិវិធី ដែលមានចែង នៅក្នុងអនុក្រឹត្យ ។

## VI. អវសានបញ្ញត្តិ :

ក្រោយពីបានទទួលនូវសារាចរណែនាំនេះ រាល់អាជ្ញាធរដែនដី គ្រប់បណ្តាថ្នាក់ និងកងកម្លាំងនគរបាលជាតិទាំងអស់ក្រោមឱវាទក្រសួងមហាផ្ទៃ ត្រូវយកចិត្តទុកដាក់ ធ្វើការណែនាំជំរុញ ការផ្សព្វផ្សាយអោយបានយល់ដឹងពីគោលការណ៍របស់រាជរដ្ឋាភិបាល ដែលបានពង្រឹងលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដល់គ្រប់បណ្តាមូល ដ្ឋានថ្នាក់ក្រោមសំរាប់អនុវត្តឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានិងព្រះហស្តលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ**

**ចម្លងជូន :**

-ទីស្តីការគណៈរដ្ឋមន្ត្រី ( ដើម្បីជូនជ្រាប)
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
-អគ្គស្នងការដ្ឋាននគរបាលជាតិ
-អគ្គនាយកដ្ឋានរដ្ឋបាលស៊ីវិល
-អគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល
-អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ
-នាយកដ្ឋានផែនការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-គ្រប់សាលាខេត្ត-ក្រុង ( ដើម្បីអនុវត្ត)
-គ្រប់ស្នងការដ្ឋាននគរបាលខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧៣៧៥ ពណ.ឧតក

ភ្នំពេញថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **បន្ទាយស្រី សុវណ្ណនី អ៊ីមផត អិចផត**

**BANTEAY SREY SOVANNY IMPORT EXPORT Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8116/05P ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **រិន សុវណ្ណនី**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៤៦៨ ភូមិកាប់គោថ្មី ឃុំអូរចារ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្តវីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស-សេវា[illegible]ទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រសិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។៚

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គីម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាខេត្តបាត់ដំបង
- មន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៧៦៩ ពណ.នគក

ភ្នំពេញថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០០៥

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ជំរាបមក**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលិកលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ខេថឺរីង អេឃ្វីបមេន សេល & សឺវីស**

**CATERING EQUIPMENT SALES & SERVICES Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2609/05E ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក CHUA CHEAN MENG ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី TAN GAIK ENG អភិបាល

លោក **ធ្វី សុខ** "តតិយជន" អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៥០ ផ្លូវជាតិលេខ ៥ សង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកបរិវត្តពាណិជ្ជកម្ម

-សេវារកការងារជូនអត្តពលិកនៅក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស-សេវាបញ្ជូននិងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។៚

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា
- ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៦៣៧០ ពណ.នគក

ភ្នំពេញថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០០៥

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេស អេស ស៊ី ៨៨៨៨ (ខេមបូឌា)**
**SSC 8888 ( CAMBODIA ) Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8101/05P ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន :
- លោក **យន់ តារាធី** ប្រធានក្រុមប្រឹក្សាភិបាល
- លោក BORWORN KHAENGKHAN អភិបាល
- លោក **ឡាយ ដារ៉ា** អភិបាល
- លោកស្រី SUPHATCHA CHAROENCHAI អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៣៩៦ Eo ផ្លូវជាតិលេខ ៥ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-វិនិយោគកំពង់ផែនិងផែស្ងួត
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ-ពិសេស ប្រេងឥន្ធនៈរថយន្ត ទោចក្រយានយន្ត ត្រីចក្រយានយន្ត សំភារៈបរិក្ខារសំណង់ ស៊ីម៉ង់ត៍ គ្រឿងដែក គ្រឿងឈើ គ្រឿងថ្ម គ្រឿងសង្ហារឹម សំភារៈបរិក្ខារអគ្គីសនី និង អេឡិចត្រូនិច CD VCD គ្រឿងឧបភោគបរិភោគ ចំណីសត្វ ថ្នាំសម្លាប់ សត្វល្អិត និង ជីគីមីបំរើអោយវិស័យកសិកម្ម ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការដួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់ផ្នែករដ្ឋបាលពាណិជ្ជកម្ម
-សេវាផ្នែកពត៌មានវិទ្យា

-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស-សេវាបញ្ជូននិងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម មជ្ឈមណ្ឌលឧស្សាហកម្ម ធុនធ្ងន់ - ធុនស្រាល ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ប្រតិភូរាជរដ្ឋាភិបាល

ចាម ប្រសិទ្ធ

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៣៧១ ពណ.នគក

ភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **បេស វ៉ាន់ អ៊ិនធើប្រាយស៍**
**BEST ONE ENTERPRISE Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8119/05P ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៥

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន :
- លោក **ស្រី ចំនួនី** ប្រធានក្រុមប្រឹក្សាភិបាល
- លោក **ទឹម នេខធី** អភិបាល
- លោកស្រី **ជា រតនា** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្តវីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស ... និងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ... ថ្នល់ ...

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ